# ស្ត្រី និងភាពជាអ្នកដឹកនាំ




2 May 2024

# គោលបំណង

- អ្នកចូលរួមអាចទទួលបានចំណេះដឹង និងមានទំនុកចិត្តក្នុងការដឹកនាំតួនាទីរបស់ខ្លួនក្នុងសង្គម គ្រួសារ និងសហគមន៍ប្រកបដោយប្រសិទ្ធភាពខ្ពស់។

- សំនួរបំផុសគំនិត
- តើពូ មីង បងប្អូន ធ្លាប់បានដឹងពីពាក្យថាការដឹកនាំដែរឬទេ?
- តើពូ មីង បងប្អូន ធ្លាប់បានធ្វើការដឹកនាំដែរ ឬ ទេ?
- ឧទាហរណ៏.ការងារក្នុងគ្រួសារ សង្គម និង សហគមន៍







# ១.ការដឹកនាំ

- ដឹកនាំមានន័យថា នៅពីមុខគេ ដើម្បី តម្រង់ទិសដល់បុគ្គលិក ឬក្រុម។
- **ការដឹកនាំផ្តោតទៅលើមនុស្ស។**
  - ការដឹកនាំយកចិត្តទុកដាក់ក្នុងការដោះស្រាយបញ្ហារបស់ស្ថាប័ន (រូបភាពធំទូលាយ) និងការលើកកម្ពស់ឱ្យមានការផ្លាស់ប្តូរ។
  - **សមត្ថភាពការដឹកនាំ**

. ការស្គាល់អំពីខ្លួនឯង

. ការគ្រប់គ្រងខ្លួនឯង

. ការយល់ដឹងពីទំនាក់ទំនង

. ជំនាញទំនាក់ទំនង

2 May 2024

# យេនឌ័រ និងភេទ



- **យេនឌ័រ** សំដៅលើតួនាទី និងឥរិយាបថបុរស និងស្ត្រីដែលកំណត់ដោយសង្គម។ដោយសារតួនាទីនិងឥរិយាបថរបស់មនុស្សបាននាំឲ្យមានការកំណត់នូវទំនាក់ទំនងរវាងបុរស និងស្ត្រី។ តួនាទីទាំងនេះត្រូវបានបង្កើតឡើង និងអនុវត្តតៗគ្នាដោយមនុស្សក្នុងសង្គមដែលមានជាអាទិ៍៖ គ្រួសារ សហគមន៍ វត្តអារាម សាលារៀន សារព័ត៌មាន និងក្នុងសង្គមទាំងមូល។ យេនឌ័រអាចកែប្រែបានតាមពេលវេលា វប្បធម៌ សេដ្ឋកិច្ច និងសង្គម។ ឧទាហរណ៍៖ ស្ត្រីអាចធ្វើជាឧទ្យានុរក្ស ជាអ្នកផ្សព្វផ្សាយកសិកម្ម និងបុរសអាចជួយការងារចម្អិនអាហារបាន។
- **ភេទ** គឺសំដៅលើភាពខុសគ្នារវាងលក្ខណៈជីវសាស្ត្ររបស់បុរស និងស្ត្រី ដែលមានពីកំណើត និងមិនអាចផ្លាស់ប្ដូរបាន។ ឧទាហរណ៖ ស្ត្រីពពោះបង្កើតកូនបុរសមានគ្រាប់ពោន។

# សកម្មភាព និងការទំនាក់ទំនងរបស់ស្ត្រី





សំនួរ

១ ក្នុងផ្ទាំងរូបភាពនេះតើអ្នកបានឃើញរូបភាពអ្វីខ្លះ? តើរូបភាពនេះមានបំណងចង់បង្ហាញអំពីអ្វី?

២ តើយើងទាំងអស់គ្នាយល់បែបណា ចំពោះសកម្មភាពរបស់ស្ត្រី?

៣ តើយើងទាំងអស់គ្នាអាចធ្វើអ្វីបានខ្លះ ? ដើម្បីលើកកម្ពស់ការចូលរួមរបស់ស្ត្រី ក្នុងភាពជាអ្នកដឹកនាំ?

# ស្ត្រី និងការងារ

- ទោះបីជាធម្មតាស្ត្រីមិនទទួលបានឱកាសពេញលេញនៅក្នុងការគ្រប់គ្រងលើធនធានផលិតកម្មរបស់ខ្លួនប៉ុន្តែផលិតផលរបស់គាត់នៅតែអាចយកទៅលក់លើទីផ្សារបាន។
- ស្ត្រីមិនសូវទទួលបានការផ្សព្វផ្សាយជំនាញកសិកម្មទេប៉ុន្តែការងារស្រែចម្ការគាត់ជាអ្នករាប់រងយ៉ាងសកម្ម និងចូលរួមធ្វើការសម្រេចចិត្ត។
- ស្ត្រីទទួលខុសត្រូវលើការប្រមូលផលនិងផលដែលផលិតបាននិងធ្វើការទំនាក់ទំនងជាមួយអ្នកទិញក្នុងភូមិឬខាងក្រៅ។
- ដើម្បីលើកកម្ពស់ការចូលរួមរបស់ស្ត្រីក្នុងភាពជាអ្នកដឹកនាំ

# ដើម្បីលើកកម្ពស់ការចូលរួមរបស់ស្ត្រីក្នុងភាពជាអ្នកដឹកនាំ:

- សហគមន៍ត្រូវផ្តល់ឱកាសឲ្យស្ត្រីបានចូលរួមក្នុងការងារ ស្មើគ្នាជាមួយបុរស
- សង្គម និងសហគមន៍ត្រូវផ្លាស់ប្តូរ ឥរិយាបថដែលតែងប្រព្រឹត្ត និងគិតថា ការងារផ្ទះជាការងាររបស់ស្ត្រី ហើយបុរសត្រូវជួយការងារផ្ទះទាំងអស់គ្នា។
- គ្រួសារ ត្រូវផ្តល់ឱកាស និងលើកទឹកចិត្តឲ្យស្ត្រី និងក្មេងស្រីបានរៀនសូត្រជ្រៅជ្រះ
- ស្ត្រីត្រូវ មានចំណេះដឹង ជំនាញ សមត្ថភាព ឆន្ទៈ ភាពក្លាហាននិងការទទួលខុសត្រូវ។

# ការអប់រំរបស់ស្ត្រីនិងក្មេងស្រី



សំនួរ

១ ក្នុងផ្ទាំងរូបភាពនេះតើអ្នកបានឃើញរូបភាពអ្វីខ្លះ? តើរូបភាពនេះមានបំណងចង់បង្ហាញអំពីអ្វី?

២ តើកត្តារាំងអ្វីខ្លះ ដែលធ្វើអោយស្រ្តីទទួលបានការសិក្សាតិចជាងបុរស?

៣ តើយើងទាំងអស់គ្នាត្រូវធ្វើអ្វីខ្លះ ដើម្បីលើកកម្ពស់ការចូលរួមរបស់ស្រ្តីក្នុងការអប់រំ?

# ការអប់រំរបស់ស្ត្រីនិងក្មេងស្រី

ស្ត្រីទទួលបានការសិក្សារតិចជាងបុរស។ បញ្ហានេះជាកត្តាមួយក្នុងការរាំងដល់លទ្ធភាពទទួលបានព័ត៌មាន ដើម្បីបង្កើនចំនេះដឹងផ្ទាល់ខ្លួនរបស់ស្ត្រី។ ជាទូទៅអនក្ខរភាពឬភាពមិនចេះអក្សរក្នុងចំណោមស្ត្រីខ្ពស់ជាងបុរសដែលធ្វើឲ្យលទ្ធភាពរបស់ស្ត្រីទទួលបានប្រាក់ចំណូលពីការងារ និងចំណេះដឹងមានតិចតួច។

- មានមូលហេតុជាច្រើនដែលរាំងស្ត្រីដូចជា៖
  - ឪពុកម្ដាយមិនឲ្យតម្លៃលើការសិក្សារបស់ក្មេងស្រី
  - កូនស្រីមានការទទួលខុសត្រូវមើលថែប្អូន និងជួយការងារផ្ទះ

ពេលម្ដាយរវល់ការងារស្រែចម្ការ

- សង្គមនិងសហគមន៍គិតថា កូនស្រីមិនចាំបាច់រៀនច្រើន
- សាលារៀននៅឆ្ងាយ និងបារម្ភពីសុវត្ថិភាពកូនស្រី
- រៀបការនៅវ័យក្មេង។

❖ ដើម្បីលើកកម្ពស់ការចូលរួមរបស់ស្ត្រីក្នុងការងារអប់រំ

- ឪពុកម្ដាយត្រូវឲ្យតម្លៃលើការសិក្សារបស់ក្មេងស្រី
- ឪពុកម្ដាយត្រូវផ្ដល់ឪកាស និងជំរុញកូនស្រីរៀនសូត្របានច្រើន
- ត្រូវមានផែនការគ្រួសារច្បាស់លាស់ មុនសម្រេចចិត្តរៀបការ

# យេនឌ័រ និងការងារស្ត្រី



សំនួរ

១ ក្នុងផ្ទាំងរូបភាពនេះតើអ្នកបានឃើញរូបភាពអ្វីខ្លះ? តើរូបភាពនេះមានបំណងចង់បង្ហាញអំពីអ្វី?

២ តើការចូលរួមរបស់ស្រ្តីក្នុងការធ្វើសេចក្តីសម្រេចចិត្តមានសារៈសំខាន់ដូចម្តេចខ្លះ

៣ តើយើងទាំងអស់គ្នា អាចធ្វើអ្វីខ្លះដើម្បីលើកកម្ពស់ការចូលរួមរបស់ស្រ្តីក្នុងការធ្វើសេចក្តីសម្រេចចិត្ត ក្នុងការងារគ្រួសារ សង្គម និងសហគមន៍

- ការចូលរួមរបស់ស្ត្រី ធ្វើអោយមានការកាត់បន្ថយផ្នត់គំនិតសង្គម ការរើសអើងភេទ គម្លាតការងារ ធ្វើអោយមានចំនួនស្ត្រីចូលរួម ការងារសហគមន៍។ រាល់ការអភិវឌ្ឍន៍ មិនមានការមើលរំលងពីតម្រូវការរបស់ស្ត្រី។ បច្ចុប្បន្នការចូលរួមរបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្តមានសារៈសំខាន់ណាស់ ទាំងក្នុងសង្គមគ្រួសារ សហគមន៍ និងសង្គមទាំងមូលមិនអាចខ្វះបាន ។
- ដើម្បីលើកកម្ពស់ការចូលរួមរបស់ ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្តក្នុងការងារគ្រួសារ សង្គម និងសហគមន៍យើងត្រូវ ៖
  - គ្រួសារ ជួយរំលែកបន្ទុកគ្រួសារ ធ្វើអោយស្ត្រីមានពេលវេលាចូលរួមក្នុងការងារសហគមន៍បានពេញលេញ។
  - គាំទ្រ និងលើកទឹកចិត្តស្ត្រី

- គាំទ្រ និងលើកទឹកចិត្តស្ត្រី
- ផ្តល់ឱកាសឲ្យស្ត្រីបានចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា កិច្ចប្រជុំ នឹងការងារសង្គមដើម្បីពង្រឹងសមត្ថភាពបន្ថែម
- ផ្តល់ឱកាសឲ្យស្ត្រីបានឈរឈ្មោះជាតំណាង នៅតាមសហគមន៍
- ផ្តល់អាទិភាពឲ្យស្ត្រីក្នុងឱកាសការងារ
- ផ្តល់រង្វាន់លើកទឹកចិត្ត ( ប័ណ្ណសសើរ ឬប្រាក់រង្វាន់ )

2 May 2024

# សិទ្ធ និងការចូលរួមរបស់បុរសស្ត្រី




2 May 2024

សំនួរ

១ តើអ្នកធ្លាប់ស្គាល់រូបភាពតំណាងទាំងអស់នេះទេ?

២ តើយើងទាំងអស់គ្នាបានដឹងថាមានច្បាប់ការពារ និង លើកកម្ពស់សិទ្ធិស្មើគ្នាចំពោះមុខច្បាប់ មានសេរីភាពស្មើគ្នា បំពេញ កាតព្វកិច្ចដូចគ្នា មិនរើសអើងភេទ និង ពូជសាសន៍ដែរឬទេ?

**រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៣១** បានចែងថាប្រជាពលរដ្ឋខ្មែរគ្រប់រូបមានសិទ្ធស្មើគ្នានៅចំពោះមុខច្បាប់មានសេរីភាពដូចគ្នានិងបំពេញកាតព្វកិច្ចដូចគ្នាដោយមិនគិតពីពូជសាសន៍ ពណ៌សម្បុរភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើត ស្ថានភាពសង្គម ទ្រព្យសម្បត្តិឬស្ថានភាពផ្សេងទៀត។

**សេចក្តីប្រកាសស្តីពីសិទ្ធជនជាតិដើមភាគតិច មាត្រា២ និងមាត្រា២១ ចំណុច១ និង២** បានចែងអំពីការធានាដល់ជនជាតិដើមភាគតិចគ្រប់រូបនូវសេរីភាព និងសមភាពដូចគ្រប់ជាតិសាសន៍ដទៃ ដោយផ្អែកលើអត្តសញ្ញាណរបស់គាត់ និងគ្មានការរើសអើងក្នុងការចូលរួមនៅក្នុងវិ

- ស័យសេដ្ឋកិច្ច សង្គមរួមទាំងការអប់រំ ការបណ្ដុះបណ្ដាលវិជ្ជាជីវៈ មានលំនៅដ្ឋានសមរម្យ អនាម័យ សុខភាព។សេចក្ដីប្រកាសនេះបានចែងអំពីតួនាទីរដ្ឋក្នុងការចាត់វិធានការពិសេសនៅពេលដែលសមស្រប ដើម្បីធានាឲ្យប្រសើរឡើងនូវស្ថានភាពសេដ្ឋកិច្ច និងសង្គមរបស់ក្រុមជនជាតិដើមភាគតិច ជាពិសេសការយកចិត្តទុកដាក់ដល់តម្រូវការចាំបាច់របស់មនុស្សចាស់ ស្ត្រី យុវជន កុមារ និងជនពិការ និងចាត់វិធានការដើម្បីធានាថាស្ត្រី និងកុមារទទួលបាននូវការ ការពារប្រឆាំងនឹងរាល់ទម្រង់នៃអំពើហិង្សា និងការរើសអើង។
- **អនុសញ្ញាស្តីអំពីការលុបបំបាត់រាល់ទម្រង់ នៃការរើសអើងប្រឆាំងទៅនឹងស្ត្រី មាត្រា២ចំណុច(ច)នឹងមាត្រា៥ បាននិយាយអំពីការចាត់វិធានការ**

2 May 2024

សមស្របទាំងអស់រួមទាំងច្បាប់ដើម្បីកែប្រែឬលុបចោលច្បាប់ដែលមានស្រាប់បទប្បញ្ញត្តិទំនៀមទម្លាប់ និងការអនុវត្តដែលបង្កឲ្យមានការរើសអើងប្រឆាំងនឹងនារី ហើតធ្វើការកែប្រែគំរូសង្គម និងវប្បធម៌នៃការប្រព្រឹត្តិរបស់បុរស និងស្ត្រីដើម្បីឈានដល់ការលុបបំបាត់ការប្រកាន់ពូជសាសន៍ និងទំនៀមទម្លាប់ប្រពៃណី និងការអនុវត្តផ្សេងៗទៀតដែលជាផ្នត់គំនិតរើសអើងភេទបុរសនិងស្ត្រី។

2 May 2024

# ភាពស្មើគ្នារវាងបុរស និងស្ត្រី



សំនួរ

១ ក្នុងផ្ទាំងរូបភាពនេះតើអ្នកបានឃើញរូបភាពអ្វីខ្លះ? តើរូបភាពនេះមានបំណងចង់បង្ហាញអំពីអ្វី?

២ ដើម្បីលើកកម្ពស់ការចូលរួមរបស់ស្ត្រីឲ្យស្មើភាពនឹងបុរសក្នុងការដឹកនាំ និងការធ្វើសេចក្តី សម្រេចចិត្ត តើយើងត្រូវធ្វើដូចម្តេចខ្លះ?

- ផ្លាស់ប្តូរគំនិតនិងឥរិយាបថ៖ យើងត្រូវផ្លាស់ប្តូរការគិត និងឥរិយាបថដែលយល់ថាការងារផ្ទះសំបែងជាការងាររបស់ស្ត្រី។ទាំងបុរស និងស្ត្រីរួមគ្នាធ្វើការងារផ្ទះមានដូចជា ដងទឹករកអុសដឹកជញ្ជូនអុស មើលថែកូនចៅ ចម្អិនអាហារ។ ធ្វើបែបនេះទើបអាចឲ្យស្ត្រីមានពេលវេលាមកទទួលការបណ្តុះបណ្តាល និងចូលរួមការងារសង្គម។
- បង្កើនការយល់ដឹងរបស់ស្ត្រីនិងក្មេងស្រី៖ យើងត្រូវពង្រីកការយល់ដឹងក្នុងចំនោមស្ត្រី និងក្មេងស្រីនូវសកម្មភាពពាក់ព័ន្ធនឹងសហគមន៍ហើយត្រូវតែកសាងចំណេះដឹងអំពីការចូលរួមសហគមន៍។យើងក៏ត្រូវជំរុញ ឲ្យមានការចូលរួមនិងគាំទ្រទាំងស្រុងរបស់បុរស និងកុមារា ដើម្បីធ្វើឲ្យមានការចូលរួមយ៉ាងពេញលេញពីស្ត្រីនិងកុមារីនៅក្នុងការសម្រេចចិត្ត។

- លើកទឹកចិត្តឲ្យស្ត្រីចូលរួមក្នុងការងារសម្រេចចិត្ត៖ យើងត្រូវលុបបំបាត់គំនិតដែលថាស្ត្រីវិលចង្ក្រានមិនជុំ និងឲ្យបុរសជួយចែករំលែកការងារក្នុងផ្ទះ ជំរុញលើកទឹកចិត្តឲ្យស្ត្រីចូលរួមការងារ សង្គម និងសហគមន៍ឲ្យបានច្រើនផ្សារភ្ជាប់ការងារក្នុងផ្ទះ និងការងារសហគមន៍ដល់ស្ត្រី ដើម្បីបង្កើនចំណេះដឹង រៀនបង្កើតទំនាក់ទំនង រៀនចចារក្នុងសហគមន៍។

# សំណួរ ចម្លើយ



# សូមអរគុណ!!!